# ឧបេក្ខាចិត្ត

| | |
|---|---|
| តាំងចិត្តនឹងមាំស្ងប់ | កុំឲ្យស្អប់កុំស្រឡាញ់ |
| ឧបេក្ខាចិត្តវិញ | មានសតិ សម្បជញ្ញៈ ។ |
| ឃើញរូបឮសំឡេង | មិនវង្វេងជាប់ជំពាក់ |
| ក្លិន រស ផោដ្ឋព្វៈ | និង ធម្មៈ កើតក្នុងចិត្ត ។ |
| ទោះបី ខ្មៅ ឬ ស | អាក្រក់ ល្អ ដ៏ប្រណីត |
| មិនអាចអូសទាញចិត្ត | ឲ្យស្រឡាញ់ឬស្អប់ឡើយ។ |
| អ្នកធ្វើបានយ៉ាងនេះ | ឃើញធម៌ច្បាស់ប្រាកដហើយ |
| ដល់ទីពឹងត្រាណត្រើយ | សុខឥតស្បើយនិព្វានហោង៕ |

**ចាកឧបករណ៍ សមថ វិបស្សនា ឆ្នាំ ២០០២**

| | |
|---|---|
| កុំដេករង់ចាំ កុំខំប្រាថ្នា | ត្រូវតែឧស្សាហ៍បដិបត្តិធម៌ |
| ធ្វើរៀងរាល់ថ្ងៃទើបបានក្ដីល្អ | មង្គលបវរកើតឡើងពុំខាន៕ |

# សទ្ធា និង បញ្ញា

| | |
|---|---|
| មានតែសទ្ធាអត់បញ្ញា | ដូចឆ្មេចនេត្រាដើរពេលយប់ |
| គេចមិនផុតទេតែងជំពប់ | ជឿច្រើនជ្រុលជ្រប់ **ចាញ់បោកគេ។** |
| មានតែបញ្ញាអត់សទ្ធា | ដូចអត់គ្នីគ្នាជួយកាញ់គ្នេរ |
| បញ្ញាម្នាក់ឯងតែងជ្រៀងជ្រេ | ទេរទៅជា **មិច្ឆាទិដ្ឋិ៕** |

**ចាកពុទ្ធសាសនា រុងរឿង ឬ រោយរៀវ ឆ្នាំ ២០០២**

| | |
|---|---|
| **មធុវា មញ្ញតី ពាលោ** | **យាវ បាបំ ន បច្ចតិ** |
| **យទា ច បច្ចតី បាបំ** | **អថ ទុក្ខំ និគច្ឆតិ ។** |
| ពេលដែលបាបមិនទាន់ឲ្យផល | ជនពាលសំគាល់ដូចទឹកឃ្មុំ |
| លុះបាបឲ្យផលពាលទួញយំ | រងទុក្ខក្ដៅធំព្រោះបាបផ្ដល់ ។ |